គ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ

**អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី**

**LOLC (Cambodia) Plc.**

# របាយការណ៍ប្រចាំត្រីមាសទី៣

## គិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩

គំនិតរីកចម្រើន *Ideas for Growth*

# មាតិកា


ព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... 2

ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប ..... 3

សមាសភាពក្រុមប្រឹក្សាភិបាល ..... 3

សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល ..... 5

សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ ..... 7

**ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ** ..... 9

ក-អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ ..... 9

ខ-លក្ខណៈនៃធុរកិច្ច ..... 9

គ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ ..... 9

**ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច** ..... 10

ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក ..... 10

ខ-រចនាសម្ព័ន្ធចំណូល ..... 10

**ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ** ..... 11

**ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង** ..... 12

ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ ..... 12

ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ ..... 14

គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល ..... 14

ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ ..... 14

ង-ផលប៉ះពាល់នៃអតិផរណា ..... 14

ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល ..... 14

**ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)** ..... 15

**ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ** ..... 16

## ព័ត៌មានហិរញ្ញវត្ថុសង្ខេប

| ស្ថានភាពហិរញ្ញវត្ថុ | ត្រីមាសទី៣ ឆ្នាំ២០១៩ | ២០១៨ |
|---|---|---|
| ទ្រព្យសកម្មសរុប (លានរៀល) | 3,630,980 | 2,443,915 |
| បំណុលសរុប (លានរៀល) | 3,137,531 | 2,126,156 |
| មូលធនសរុប (លានរៀល) | 493,449 | 317,759 |
| **លទ្ធផលហិរញ្ញវត្ថុ** | **ត្រីមាសទី៣ ឆ្នាំ២០១៩** | **ត្រីមាសទី៣ ឆ្នាំ២០១៨** |
| ចំណូលការប្រាក់ (លានរៀល) | 109,988 | 82,255 |
| ចំណេញ/(ខាត) មុនបង់ពន្ធ (លានរៀល) | 42,899 | 18,337 |
| ចំណេញ/(ខាត) សុទ្ធក្នុងការិយបរិច្ឆេទ (លានរៀល) | 33,035 | 12,596 |

| អនុបាតហិរញ្ញវត្ថុ (សម្រាប់គ្រឹះស្ថានធនាគារ និងហិរញ្ញវត្ថុ) | ត្រីមាសទី៣ ឆ្នាំ២០១៩ | ឆ្នាំ២០១៨ |
|---|---|---|
| អនុបាតសាធនភាព | 15.59% | 15.63% |
| អនុបាតបំណុលធៀបនឹងមូលធន | 6.36 | 6.69 |
| អនុបាតសន្ទនីយភាព | 243.38% | 234.00% |
| អនុបាតឥណទានមិនដំណើរការ | 0.92% | 0.96% |
| អនុបាតបញ្ញើឥណទាន | 57.30% | 47.74% |
| | **ត្រីមាសទី៣ ឆ្នាំ២០១៩** | **ត្រីមាសទី៣ ឆ្នាំ២០១៨** |
| អនុបាតចំណេញធៀបនឹងទ្រព្យសកម្ម | 1.09% | 0.68% |
| អនុបាតចំណេញធៀបនឹងមូលធន | 8.14% | 4.78% |
| អនុបាតលទ្ធភាពបង់ការប្រាក់ | 176% | 143% |
| ចំណេញក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | N/A | N/A |
| ភាគលាភក្នុងមួយឯកតាមូលបត្រកម្មសិទ្ធិ (ករណីចុះបញ្ជីលក់មូលបត្រកម្មសិទ្ធិ) | N/A | N/A |
| អនុបាតហិរញ្ញវត្ថុសំខាន់ៗផ្សេងទៀត (ប្រសិនមាន) | N/A | N/A |

# ក្រាហ្វិកអំពីព័ត៌មានហិរញ្ញវត្ថុសង្ខេប


















## សមាសភាពក្រុមប្រឹក្សាភិបាល



លោក ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា
ប្រធានក្រុមប្រឹក្សាភិបាល



លោក ខនរ៉ាត ដាយអឺស
អភិបាល



លោក ឌូលីប រ៉ាស៊ីកា សាម៉ារ៉ាវីរ៉ា
អភិបាល



លោក អ៊ីនដ្រាជីត វីជេស៊ីរីវ៉ាដាណា
អភិបាលឯករាជ្យ



លោក ម៉ៃឃើល ម័រម៉ែន
អភិបាលឯករាជ្យ

# សេចក្តីថ្លែងរបស់ប្រធានក្រុមប្រឹក្សាភិបាល

ខ្ញុំបាទមានសេចក្តីសោមនស្សរីករាយក្នុងការបង្ហាញនូវលទ្ធផលសម្រេចបានរបស់ អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី សម្រាប់ត្រីមាសទី៣ ឆ្នាំ២០១៩។ ក្នុងនាមជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើទី២ នៅក្នុងប្រទេសកម្ពុជា ដែលបោះផ្សាយលក់មូលបត្របំណុល (ដែលមានទំហំ ៨០ ប៊ីលានរៀល ឬសមមូលនឹង ២០លានដុល្លារអាមេរិក) អិលអូអិលស៊ីប្តេជ្ញាចិត្តក្នុងការផ្តល់នូវផលិតផលហិរញ្ញវត្ថុថ្មីៗ ព្រមទាំងលើកកម្ពស់ការប្រើប្រាស់ប្រាក់រៀលផងដែរ។

គិតត្រឹមត្រីមាសទី៣ ឆ្នាំ២០១៩ អិលអូអិលស៊ី (ខេមបូឌា) បន្តរក្សាបាននូវលទ្ធផលហិរញ្ញវត្ថុ និងសង្គមគួរជាទីគាប់ចិត្ត។ ជាមួយនឹងការអនុវត្តគោលនយោបាយយុទ្ធសាស្ត្រ ក្នុងគោលបំណងលើកកម្ពស់វិស័យសហគ្រាសធុនតូច និងមធ្យម ដែលកំពុងតែរីកចម្រើនយ៉ាងឆាប់រហ័ស និងការគ្រប់គ្រងផ្ទៃក្នុងយ៉ាងមានប្រសិទ្ធភាព អិលអូអិលស៊ី (ខេមបូឌា) បានបង្កើនផលប័ត្រឥណទានដល់ចំនួន ៦៩១ លានដុល្លារអាមេរិក ដែលមានកំណើន ៤២% ធៀបនឹងចុងឆ្នាំ ២០១៨។ ហានិភ័យផលប័ត្រឥណទាន ៣០ថ្ងៃ មានអត្រា ០,៩២% ដែលទាបជាងអត្រាហានិភ័យជាមធ្យម នៅក្នុងវិស័យទាំងមូល។ ជាមួយនឹងកំណើនយ៉ាងឆាប់រហ័ស និងប្រកបដោយគុណភាព អិលអូអិលស៊ី (ខេមបូឌា) បានក្លាយជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេលំដាប់ទី៤ នៅក្នុងប្រទេសកម្ពុជា គិតលើចំនួនផលប័ត្រឥណទាន និងសមតុល្យប្រាក់បញ្ញើ និងជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំជាងគេលំដាប់ទី៣ បើគិតលើចំនួនអតិថិជន ខណៈដែលអត្រាចំណេញពីទ្រព្យសកម្មរបស់អិលអូអិលស៊ីទទួលបានលទ្ធផលល្អឈានមុខគេ ក្នុងចំណោមគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើដែលធំជាងគេទាំង៧ ហើយអត្រាចំណេញពីមូលធនភាគទុនិក របស់អិលអូអិលស៊ីជាប់លំដាប់ថ្នាក់លេខ២ ពីរឆ្នាំជាប់គ្នានៅក្នុងឆ្នាំ២០១៧ និងឆ្នាំ២០១៨។

ក្នុងអំឡុងឆ្នាំ២០១៩ អិលអូអិលស៊ីបានពង្រីកអាជីវកម្ម និងសេវាកម្មរបស់ខ្លួន ជាមួយនឹងការបង្កើតផលិតផលដើម្បីឆ្លើយតបទៅនឹងតម្រូវការរបស់អតិថិជនដែលមានចំណូលកម្រិតមធ្យម ដែលមានការកើនឡើងយ៉ាងឆាប់រហ័ស។ ការរីកចម្រើនក្នុងវិស័យសហគ្រាសធុនមធ្យមធ្វើឱ្យមានតម្រូវការផលិតផលកាន់តែទំនើប និងសម្បូរបែបជាងមុន។ ជាមួយនឹងការគាំទ្រផ្នែកបច្ចេកទេសពីអិលអូអិលស៊ីគ្រុប អិលអូអិលស៊ី (ខេមបូឌា) នឹងបន្តកែលម្អផលិតផល និងសេវាកម្មដែលមានស្រាប់ ដើម្បីបំពេញតាមតម្រូវការរបស់អតិថិជន។ លើសពីនេះទៅទៀត អិលអូអិលស៊ីនឹងបន្តពង្រឹងសេវាអតិថិជន និងផ្តល់ផលិតផលព្រមទាំងសេវាកម្មថ្មីៗសម្បូរបែបទៅតាមតម្រូវការទីផ្សារ រួមមាន គណនីសន្សំសម្រាប់ប្រើប្រាស់ក្នុងគម្រោងពេលអនាគត គណនីសន្សំសម្រាប់បុត្រធីតា និង សេវាទូទាត់វិក្កយបត្រ។ អិលអូអិលស៊ីមានទស្សនវិស័យសម្រាប់ឆ្នាំ២០១៩ នេះជាឆ្នាំសម្រាប់សេវាហិរញ្ញវត្ថុឌីជីថលដែលធ្វើឱ្យសេវាអតិថិជន របស់យើងកាន់តែល្អប្រសើរឡើងមួយកម្រិតទៀត និងបង្កើនប្រសិទ្ធភាពតាមរយៈការប្រើប្រាស់សេវាហិរញ្ញវត្ថុឌីជីថល។

ឆ្លៀតក្នុងឱកាសនេះ ខ្ញុំបាទសូមថ្លែងអំណរគុណដល់សមាជិកក្រុមប្រឹក្សាភិបាលទាំងអស់ សម្រាប់ការដឹកនាំ និងការផ្តល់នូវទិសដៅយុទ្ធសាស្ត្រ ដែលបង្កើនសមត្ថភាពគ្រប់គ្រងរបស់អិលអូអិលស៊ី (ខេមបូឌា) ក្នុងការសម្រេចបាននូវកំណើន និងលទ្ធផលហិរញ្ញវត្ថុយ៉ាងល្អប្រសើរជាប្រចាំ។ ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ប្រធាននាយកប្រតិបត្តិ អនុប្រធាននាយកប្រតិបត្តិ/ប្រធាននាយកហិរញ្ញវត្ថុ គណៈគ្រប់គ្រងជាន់ខ្ពស់ និងបុគ្គលិកទាំងអស់ សម្រាប់ការគាំទ្រ ការខិតខំប្រឹងប្រែង និងការប្តេជ្ញាចិត្តដ៏រឹងមាំ ដែលធ្វើអិលអូអិលស៊ីទទួលបានជោគជ័យដូចសព្វថ្ងៃនេះ។

ខ្ញុំបាទក៏សូមថ្លែងអំណរគុណដល់ធនាគារជាតិនៃកម្ពុជា និងគណៈកម្មការមូលបត្រនៃកម្ពុជា សម្រាប់ការគាំទ្រ និងការផ្តល់អនុសាសន៍។

ជាចុងក្រោយ ខ្ញុំបាទសូមអរគុណដល់ម្ចាស់ភាគទុនិក អតិថិជនប្រាក់បញ្ញើ វិនិយោគិន និងដៃគូពាក់ព័ន្ធទាំងអស់ សម្រាប់ការជឿទុកចិត្ត និងភាពជឿជាក់ដែលមានមកលើអិលអូអិលស៊ី ហើយខ្ញុំបាទជឿជាក់ថាអតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធទាំងអស់នឹងនៅតែបន្តការគាំទ្រអិលអូអិលស៊ីបន្តទៅមុខជាយូរអង្វែងទៀត។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០១៩

ហត្ថលេខា ត្រា និងឈ្មោះប្រធានក្រុមប្រឹក្សាភិបាល

ប្រ៊ីនលី ដេ ហ្ស៊ីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

# សេចក្តីថ្លែងរបស់ប្រធាននាយកប្រតិបត្តិ

គិតត្រឹមដំណាច់ត្រីមាសទី៣ ឆ្នាំ២០១៩ អិលអូអិលស៊ីរក្សាបាននូវកំណើនប្រកបដោយគុណភាព ដែលផលប័ត្រឥណទានកើនឡើងដល់ ៦៩១ លានដុល្លារអាមេរិក ដែលមានអត្រាកំណើន ៤២% ធៀបនឹងដំណាច់ឆ្នាំ២០១៨។ ហានិភ័យផលប័ត្រឥណទានមានអត្រាត្រឹមតែ 0,៩២% ដែលទាបជាងអត្រាហានិភ័យជាមធ្យមនៅក្នុងវិស័យមីក្រូទាំងមូល។ ចំនួនអតិថិជនកើនឡើង ១៩% ដល់ចំនួន ២៧៩.៧០៤ នាក់។ ទ្រព្យសកម្មសរុបរបស់អិលអូអិលស៊ីកើនឡើងដល់ ចំនួន ៨៨៦ លានដុល្លារអាមេរិក គិតត្រឹមដំណាច់ខែកញ្ញា ឆ្នាំ២០១៩។ សមតុល្យប្រាក់បញ្ញើកើនឡើងយ៉ាងឆាប់រហ័សដល់ជាង ៣៩៦ លានដុល្លារអាមេរិក ដែលមានអត្រាកំណើន ៧០% ធៀបនឹងដំណាច់ឆ្នាំ២០១៨ ខណៈដែលចំនួនអតិថិជនប្រាក់បញ្ញើកើនឡើងដល់ ៣០២.៤១៥ នាក់ ដែលមានអត្រាកំណើន ៦៨%។ កំណើនយ៉ាងឆាប់រហ័សនៃផលប័ត្រឥណទាន និងសមតុល្យប្រាក់បញ្ញើសន្សំបង្ហាញឱ្យឃើញថា អិលអូអិលស៊ីគឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុដែលគួរឱ្យទុកចិត្តខ្ពស់ ដែលផ្តល់នូវសេវាហិរញ្ញវត្ថុដ៏ល្អប្រសើរដល់អតិថិជន ការពារអតិថិជន និងផ្តល់នូវផលិតផលប្រាក់បញ្ញើ និងផលិតផលឥណទានថ្មីៗ ដែលមានលក្ខណៈប្រកួតប្រជែង។

អិលអូអិលស៊ីបានពង្រីកបណ្តាញប្រតិបត្តិការរបស់ខ្លួនដល់ ៧៨ការិយាល័យសាខានៅទូទាំងប្រទេស និងមានបុគ្គលិកជាង ២.៧០០ នាក់ កំពុងផ្តល់សេវាហិរញ្ញវត្ថុដ៏ល្អបំផុតជូនដល់អតិថិជន។

នៅក្នុងឆ្នាំ២០១៩ នេះ អិលអូអិលស៊ីនឹងផ្តោតសំខាន់លើការប្រើប្រាស់ប្រព័ន្ធបច្ចេកវិជ្ជាដែលអាចលើកកម្ពស់សេវាអតិថិជនឱ្យកាន់តែប្រសើរឡើង និងបង្កើនប្រសិទ្ធភាពការងារដូចជា Tablet, ATM, mobile banking application និង third-party connection ។

នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩ អិលអូអិលស៊ីនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធីធនាគារចល័តរបស់ខ្លួន គឺកម្មវិធី iPay Mobile Application ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានដោយខ្លួនឯងនៅក្នុងទូរស័ព្ទដៃ ដូចជាពិនិត្យមើលសមតុល្យគណនី របាយការណ៍គណនីសង្ខេប ផ្ទេរប្រាក់ ទូទាត់ការចំណាយ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ បើកគណនីបញ្ញើមានកាលកំណត់ បញ្ជាការទូទាត់តាមកាលកំណត់ គណនាប្រាក់បញ្ញើ គណនាប្រាក់កម្ចី និង បង្ហាញទីតាំងការិយាល័យ ជាដើម។

អិលអូអិលស៊ីមានគម្រោងដាក់ឱ្យប្រើប្រាស់កាត ATM ដែលអនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់កាតរបស់ខ្លួននៅគ្រប់ម៉ាស៊ីន ATM របស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធ Cambodia Share Switch - CSS ។

អិលអូអិលស៊ីនឹងដាក់ឱ្យប្រើប្រាស់ប្រព័ន្ធធនាគារ tablet banking ដែលអនុញ្ញាតឱ្យបុគ្គលិកឥណទានអនុវត្តការងារ (ដូចជាការវាយតម្លៃឥណទាន ការប្រមូលកម្ចីយឺតយ៉ាវ បើកគណនីបញ្ញើសន្សំ) ពីឧបករណ៍ tablet devices ដែលនឹងជួយបង្កើនផលិតភាព និងប្រសិទ្ធភាពការងារ។

សរុបជារួមមក យើងនឹងខិតខំប្រឹងប្រែងឱ្យអស់ពីលទ្ធភាពក្នុងការចាប់យកឱកាសជោគជ័យ ហើយយើងជឿជាក់ថា អិលអូអិលស៊ីនឹងអាចនាំមកនូវតម្លៃបន្ថែមទៀតដល់អតិថិជន វិនិយោគិន និងម្ចាស់ភាគទុនិក។

ជាចុងក្រោយ ខ្ញុំបាទសូមថ្លែងអំណរគុណដល់គណៈគ្រប់គ្រង បុគ្គលិក អតិថិជន វិនិយោគិន និងដៃគូពាក់ព័ន្ធទាំងអស់ ដែលតែងតែគាំទ្រអិលអូអិលស៊ីដើម្បីភាពរីកចម្រើនទាំងអស់គ្នា ទាំងការគាំទ្រសម្រាប់ឆ្នាំដែលកន្លងផុតទៅក៏ដូចជាការគាំទ្រដល់ភាពជោគជ័យដែលរំពឹងទុកនៅឆ្នាំបន្តបន្ទាប់ទៀត។

រាជធានីភ្នំពេញ ថ្ងៃទី ២៩ វិច្ឆិកា ឆ្នាំ ២០១៩

ហត្ថលេខា ត្រា និងឈ្មោះប្រធាននាយកប្រតិបត្តិ

ព្រះរាជាណាចក្រកម្ពុជា ក្រុមហ៊ុន អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី LOLC (CAMBODIA) Plc. KINGDOM OF CAMBODIA

**លោក សុខ ធឿន**

**ប្រធាននាយកប្រតិបត្តិ**

## ផ្នែកទី ១៖ ព័ត៌មានទូទៅពាក់ព័ន្ធនឹងបុគ្គលចុះបញ្ជីលក់មូលបត្រ

### ក-អត្តសញ្ញាណបុគ្គលចុះបញ្ជីលក់មូលបត្រ

- ឈ្មោះក្រុមហ៊ុនជាអក្សរខ្មែរ៖ **អិលអូអិលស៊ី (ខេមបូឌា) ភីអិលស៊ី** ជាអក្សរឡាតាំង៖ LOLC (Cambodia) Plc.
- អក្សរកូដ: KH2000081953 (FX-Indexed Bond) និង KH2000082951 (Plain Bond)
- ទីស្នាក់ការ៖ **អគារលេខ ៦៦B ផ្លូវលេខ ២៧១ សង្កាត់បឹងទំពុនទី២ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ**
- លេខទូរស័ព្ទ៖ (៨៥៥) ២៣ ៩៩១ ៩៩១ លេខទូរសារ៖ (៨៥៥) ២៣ ២២០ ៦៤២
- គេហទំព័រ៖ www.lolc.com.kh អ៊ីម៉ែល៖ info@lolc.com.kh
- លេខវិញ្ញាបនបត្រចុះបញ្ជីពាណិជ្ជកម្ម៖ ០០០១២៨២៩ កាលបរិច្ឆេទ៖ **ថ្ងៃទី២៨ ខែកញ្ញា ឆ្នាំ២០១៥**
- លេខអាជ្ញាបណ្ណអាជីវកម្ម៖ M.F ០៤ ចេញដោយ៖ **ធនាគារជាតិនៃកម្ពុជា** កាលបរិច្ឆេទ៖ **ថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៨**
- សេចក្តីសម្រេចអនុញ្ញាត និងចុះបញ្ជីឯកសារផ្តល់ព័ត៌មាន លេខ៖ ០៨៤/១៩ គ.ម.ក/ស.ស.រ.
  កាលបរិច្ឆេទ៖ **ថ្ងៃទី២២ ខែមេសា ឆ្នាំ២០១៩**
- ឈ្មោះបុគ្គលតំណាងបុគ្គលបោះផ្សាយ៖ **លោក សុខ រឿន**

### ខ-លក្ខណៈនៃធុរកិច្ច

អិលអូអិលស៊ី គឺជាគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុទទួលប្រាក់បញ្ញើធំមួយនៅក្នុងប្រទេសកម្ពុជា ដែលទទួលបានអាជ្ញាប័ណ្ណពីធនាគារជាតិនៃកម្ពុជា និងបានធ្វើប្រតិបត្តិការជាង ២៥ឆ្នាំមកហើយ។ អិលអូអិលស៊ីបាននឹងកំពុងផ្តល់សេវាហិរញ្ញវត្ថុយ៉ាងសម្បូរបែបដល់អតិថិជនដូចជា សេវាឥណទាន សេវាប្រាក់បញ្ញើ សេវាភតិសន្យាហិរញ្ញវត្ថុ និងសេវាផ្ទេរប្រាក់ក្នុងស្រុក តាមរយៈបណ្តាញសាខាចំនួន ៧៨សាខានៅទូទាំងប្រទេស។ គិតត្រឹមខែកញ្ញា ឆ្នាំ២០១៩ សមតុល្យប្រាក់បញ្ញើរបស់អិលអូអិលស៊ីមានចំនួនជាង ៣៩៦ លានដុល្លារអាមេរិក ជាមួយនឹងចំនួនអតិថិជនជាង ៣០២ ពាន់នាក់។ ផលប័ត្រឥណទានសរុបមានប្រមាណ ៦៩១ លានដុល្លារអាមេរិក និងមានអតិថិជនជាង ២៧៩ ពាន់នាក់។

### គ-ព្រឹត្តិការណ៍សំខាន់ៗប្រចាំត្រីមាសរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

អិលអូអិលស៊ីបាននឹងកំពុងអភិវឌ្ឍកម្មវិធីធនាគារចល័តរបស់ខ្លួនគឺ កម្មវិធី iPay mobile application ដែលអនុញ្ញាតឱ្យអតិថិជនអាចធ្វើប្រតិបត្តិការបានដោយខ្លួនឯងនៅក្នុងទូរស័ព្ទដៃ ដូចជាពិនិត្យមើលសមតុល្យគណនី របាយការណ៍គណនីសង្ខេប ផ្ទេរប្រាក់ ទូទាត់ការចំណាយ បញ្ចូលទឹកប្រាក់ក្នុងទូរស័ព្ទដៃ បើកគណនីបញ្ញើមានកាលកំណត់ បញ្ជាការទូទាត់តាមកាលកំណត់ គណនាប្រាក់បញ្ញើ គណនាប្រាក់កម្ចី និងបង្ហាញទីតាំងការិយាល័យជាដើម។ អិលអូអិលស៊ីនឹងដាក់ឱ្យប្រើប្រាស់ជាផ្លូវការនូវកម្មវិធី iPay mobile application ដល់អតិថិជនទាំងអស់នៅក្នុងត្រីមាសទី៤ ឆ្នាំ២០១៩។

បន្ថែមលើនេះ អិលអូអិលស៊ីបាននឹងកំពុងអភិវឌ្ឍប្រព័ន្ធរបស់ខ្លួន ដើម្បី តភ្ជាប់ទៅប្រព័ន្ធ Cambodia Share Switch (CSS) ដែលអនុញ្ញាតឱ្យអតិថិជនអាចប្រើប្រាស់កាត ATM របស់ខ្លួននៅគ្រប់ម៉ាស៊ីន ATM របស់គ្រឹះស្ថានដែលជាសមាជិកប្រព័ន្ធ CSS។

ទន្ទឹមនឹងនេះ អិលអូអិលស៊ីក៏កំពុង អភិវឌ្ឍប្រព័ន្ធធនាគារ tablet banking ដែល អនុញ្ញាតឱ្យបុគ្គលិកឥណទានអនុវត្តការងារ (ដូចជាការវាយតម្លៃ ឥណទាន ការប្រមូលកម្ចីយឺតយ៉ាវ បើកគណនីបញ្ញើសន្សំ) ពីឧបករណ៍ tablet device ដែលនឹងជួយបង្កើន ផលិតភាព និងប្រសិទ្ធភាពការងារ។

# ផ្នែកទី ២៖ ព័ត៌មានអំពីលទ្ធផលប្រតិបត្តិការធុរកិច្ច

## ក-លទ្ធផលប្រតិបត្តិការធុរកិច្ច ដោយរួមបញ្ចូលព័ត៌មានធុរកិច្ចតាមផ្នែក

| លទ្ធផលសម្រេចបានសំខាន់ៗ | ផែនការ | លទ្ធផលសម្រេចបាន |
|---|---|---|
| **ផ្នែកសេវាឥណទាន** | | |
| ចំនួនអតិថិជនសេវាឥណទាន | 269,607 | 279,704 |
| ឥណទាននៅក្នុងដៃអតិថិជន (លានរៀល) | 2,752,030 | 2,828,606 |
| **ផ្នែកសេវាប្រាក់បញ្ញើសន្សំ** | | |
| ចំនួនអតិថិជនប្រាក់បញ្ញើសន្សំ | 217,008 | 302,415 |
| សមតុល្យប្រាក់បញ្ញើសន្សំ (លានរៀល) | 1,508,563 | 1,620,879 |
| **ផ្នែកប្រតិបត្តិការសំខាន់ផ្សេងៗទៀត** | | |
| ចំនួនការិយាល័យ | 79 | 78 |
| ចំនួនបុគ្គលិក | 2,620 | 2,711 |

## ខ-រចនាសម្ព័ន្ធចំណូល

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ២០១៩ | | ត្រីមាសទី៣ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | 109,988 | 77.13% | 82,255 | 87.53% |
| ២ | ចំណូលផ្សេងៗ | 32,613 | 22.87% | 11,721 | 12.47% |
| ចំណូលសរុប | | **142,601** | **100%** | **93,976** | **100%** |

## ផ្នែកទី ៣៖ របាយការណ៍ហិរញ្ញវត្ថុដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ

សូមពិនិត្យមើលរបាយការណ៍លម្អិតនៅក្នុងឧបសម្ព័ន្ធដែលបានភ្ជាប់មកជាមួយ។

## ផ្នែកទី ៤៖ ការពិភាក្សា និងការវិភាគរបស់គណៈគ្រប់គ្រង

ការពិភាក្សា និងការវិភាគខាងក្រោមនេះ គឺជាការពិភាក្សាលើលទ្ធផលនៃប្រតិបត្តិការ និងស្ថានភាពហិរញ្ញវត្ថុដោយគណៈគ្រប់គ្រងរបស់អិលអូអិលស៊ី ដោយផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុគិតត្រឹមថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ ដែលបានត្រួតពិនិត្យឡើងវិញដោយសវនករឯករាជ្យ។ របាយការណ៍ហិរញ្ញវត្ថុរបស់អិលអូអិលស៊ី ត្រូវបានរៀបចំឡើងដោយអនុលោមទៅតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា និងគោលការណ៍ណែនាំរបស់ធនាគារជាតិនៃកម្ពុជា។ គណៈគ្រប់គ្រងធ្វើការពិភាក្សា និងវិភាគលើសមាសធាតុសំខាន់ៗនៃរបាយការណ៍ហិរញ្ញវត្ថុ និងកត្តាសំខាន់ៗដែលបានជះឥទ្ធិពលទៅ លើប្រាក់ចំណេញរបស់អិលអូអិលស៊ីតែប៉ុណ្ណោះ។

### ក-ទិដ្ឋភាពទូទៅនៃប្រតិបត្តិការ

#### ១-ការវិភាគចំណូល

អិលអូអិលស៊ីមានចំណូល ២ ប្រភេទធំៗ គឺចំណូលពីការប្រាក់ និងចំណូលផ្សេងៗ។

- **ចំណូលពីការប្រាក់រួមមាន៖** កម្រៃជើងសារពីឥណទាន ចំណូលការប្រាក់សុទ្ធដែលទទួលបានពីការផ្តល់ឥណទានដល់អតិថិជន និងពីការដាក់ប្រាក់បញ្ញើនៅតាមបណ្តាធនាគារនានា ដែលចំណូលទាំងនេះត្រូវទទួលស្គាល់ជាប្រចាំខែ។
- **ចំណូលផ្សេងៗរួមមាន៖** ចំណូលបានពីការផាកពិន័យ ចំណូលបានពីការប្រមូលឥណទានលុបចោល ចំណេញពីការប្តូរប្រាក់ កម្រៃផ្សេងៗ ។ល។

#### ២-ការវិភាគចំណូលតាមផ្នែក

| ល.រ | ប្រភពចំណូល | ត្រីមាសទី៣ ឆ្នាំ២០១៩ | | ត្រីមាសទី៣ ឆ្នាំ២០១៨ | |
|---|---|---|---|---|---|
| | | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ | ចំនួនទឹកប្រាក់ (លានរៀល) | ភាគរយ |
| ១ | ចំណូលការប្រាក់ | 109,988 | 77.13% | 82,255 | 87.53% |
| ២ | ចំណូលផ្សេងៗ | 32,613 | 22.87% | 11,721 | 12.47% |
| **ចំណូលសរុប** | | **142,601** | **100%** | **93,976** | **100%** |

ចំណូលពីការប្រាក់ជាចំណូលដ៏ធំ និងសំខាន់សម្រាប់អិលអូអិលស៊ី ដែលមានរហូតដល់ 77.13% នៃចំណូល សរុប។

#### ៣-ការវិភាគគម្លាតចំណេញដុល

អិលអូអិលស៊ី បានរៀបចំរបាយការណ៍លទ្ធផលរបស់ខ្លួន ក្នុងទម្រង់ជារបាយការណ៍ដែលពុំមានការបង្ហាញឱ្យឃើញនូវគំលាតចំណេញដុលនោះទេ។ ប៉ុន្តែទម្រង់របាយការណ៍នេះអាចឱ្យយើងធ្វើការពិភាក្សា និងវិភាគលើចំណេញពីប្រតិបត្តិការដែលទទួលបានពីចំណូលសរុបដកនឹងចំណាយប្រតិបត្តិការ។ ចំណាយប្រតិបត្តិការនឹងលើកយកមកពិភាក្សា និងវិភាគនៅចំណុច ៤.ការវិភាគចំណេញ/ខាតមុនបង់ពន្ធ។

## ៤-ការវិភាគចំណេញ/(ខាត) មុនបង់ពន្ធ

| តារាងសង្ខេបប្រាក់ចំណេញ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០១៩ | ត្រីមាសទី៣ ឆ្នាំ២០១៩ | បម្រែបម្រួល (លានរៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ចំណូលការប្រាក់ | 113,870 | 109,988 | (3,882) | -3.41% |
| ចំណាយការប្រាក់ | (56,493) | (56,191) | 302 | -0.53% |
| **ចំណូលពីការប្រាក់សុទ្ធ** | 57,377 | 53,797 | (3,580) | -6.24% |
| ចំណូលផ្សេងៗ | 17,026 | 32,613 | 15,587 | 91.55% |
| ចំណាយលើបុគ្គលិក | (23,971) | (26,225) | (2,254) | 9.40% |
| រំលស់លើទ្រព្យរូបី និងទ្រព្យអរូបី | (2,533) | (2,678) | (145) | 5.72% |
| ចំណាយរដ្ឋបាល និងចំណាយផ្សេងៗ | (8,749) | (9,974) | (1,225) | 14.00% |
| **ចំណេញពីប្រតិបត្តិការ** | 39,150 | 47,533 | 8,383 | 21.41% |
| សំវិធានធនលើឧបករណ៍ហិរញ្ញវត្ថុ | (4,632) | (4,634) | (2) | 0.04% |
| ប្រាក់ចំណេញមុនបង់ពន្ធ | 34,518 | 42,899 | 8,381 | 24.28% |

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ អិលអូអិលស៊ីសម្រេចបានប្រាក់ចំណេញមុនបង់ពន្ធចំនួន 42,899 លានរៀល ដែលត្រីមាសទី២ មានចំនួនត្រឹមតែ 34,518 លានរៀល ដែលកើនឡើង 8,381 លានរៀល ស្មើនឹង 24.28% ។ មូលហេតុចម្បងនៃការកើនឡើងនេះគឺដោយសារតែមានការកើនឡើងចំណូលផ្សេងៗចំនួន 15,587 លានរៀល ធៀបនឹងត្រីមាសទី២ ឆ្នាំ២០១៩។

## ៥-ការវិភាគចំណេញ/(ខាត) ក្នុងការិយបរិច្ឆេទ

| តារាងសង្ខេបប្រាក់ចំណេញ (លានរៀល) | ត្រីមាសទី២ ឆ្នាំ២០១៩ | ត្រីមាសទី៣ ឆ្នាំ២០១៩ | បម្រែបម្រួល (លានរៀល) | បម្រែបម្រួល % |
|---|---|---|---|---|
| ប្រាក់ចំណេញមុនបង់ពន្ធ | 34,518 | 42,899 | 8,381 | 32.52% |
| ចំណាយពន្ធលើប្រាក់ចំណេញ | (8,750) | (9,863) | (1,113) | -4.32% |
| ប្រាក់ចំណេញក្រោយបង់ពន្ធ | 25,768 | 33,036 | 7,268 | 28.21% |

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៩ អិលអូអិលស៊ីសម្រេចបានប្រាក់ចំណេញសុទ្ធចំនួន 33,036 លានរៀល ដែលកើនឡើង 28.21% (ពី 25,768 លានរៀល ក្នុងត្រីមាសទី២ ឆ្នាំ២០១៩)។ មូលហេតុចម្បងនៃការកើនឡើងនេះគឺដោយសារតែមានការកើនឡើងចំណូលផ្សេងៗចំនួន 15,587 លានរៀល។

## ៦-ការវិភាគពីកត្តា និងនិន្នាការដែលប៉ះពាល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុ

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ីពុំមានកត្តា និងនិន្នាការដែលប៉ះពាល់ដល់ស្ថានភាព និងលទ្ធផលហិរញ្ញវត្ថុរបស់អិលអូអិលស៊ីដែលគួរអោយកត់សម្គាល់ឡើយ។

## ខ-កត្តាសំខាន់ៗដែលប៉ះពាល់លើផលចំណេញ

### ១-ការវិភាគពីលក្ខខណ្ឌនៃតម្រូវការ និងការផ្គត់ផ្គង់

អិលអូអិលស៊ី ជាស្ថាប័នហិរញ្ញវត្ថុដ៏ធំមួយក្នុងចំណោមស្ថាប័នហិរញ្ញវត្ថុនៅក្នុងប្រទេសកម្ពុជា ដែលតែងយកចិត្តទុកដាក់ទៅលើគុណភាពនៃការផ្តល់សេវាកម្ម ដើម្បីបង្កភាពងាយស្រួលសម្រាប់អតិថិជនទូទៅក្នុងការប្រើប្រាស់ផលិតផល និងសេវារបស់អិលអូអិលស៊ី។ តាមបទពិសោធន៍នាពេលកន្លងមកនេះ អិលអូអិលស៊ី ទទួលបាននូវការគាំទ្រយ៉ាងខ្លាំងពីសំណាក់អតិថិជនប្រាក់កម្ចី អតិថិជនភតិសន្យាហិរញ្ញវត្ថុ និងអតិថិជនប្រាក់បញ្ញើ ដែលធ្វើឱ្យយើងមានការរីកចម្រើនយ៉ាងខ្លាំង និងឆាប់រហ័ស ក្នុងរយៈពេលដ៏ខ្លីចុងក្រោយនេះ។

### ២-ការវិភាគពីការឡើងចុះនៃថ្លៃវត្ថុធាតុដើម

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំមានធាតុដែលខុសពីធម្មតាទេ។

### ៣-ការវិភាគលើពន្ធ

អិលអូអិលស៊ី ស្ថិតក្រោមច្បាប់នៃក្រុមហ៊ុនពាណិជ្ជកម្មក្នុងវិស័យពន្ធដារដូចនេះ អិលអូអិលស៊ី មានភារកិច្ចបង់ពន្ធទៅតាមច្បាប់ និងបញ្ញត្តិជាធរមាន។ អិលអូអិលស៊ីមានភារកិច្ចបង់ពន្ធអាករទៅតាមរបបពិត និងសហគ្រាសជាប់ពន្ធធំ ដែលកំណត់ដោយអគ្គនាយកដ្ឋានពន្ធដារ។

### ៤-ការវិភាគលើធាតុដែលខុសពីធម្មតា និងធាតុវិសាមញ្ញ

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំមានធាតុដែលខុសពីធម្មតា និងវិសាមញ្ញនោះទេ។

## គ-ការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូល

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ីពុំមានធាតុដែលជាការប្រែប្រួលសំខាន់ៗលើការលក់ និងចំណូលខុសពីធម្មតាទេ។

## ឃ-ផលប៉ះពាល់នៃការប្តូររូបិយបណ្ណ អត្រាការប្រាក់ និងថ្លៃទំនិញ

អិលអូអិលស៊ី បានកត់ត្រាបញ្ជីគណនេយ្យដោយប្រើប្រាស់រូបិយប័ណ្ណគោលគឺ ប្រាក់រៀល។ ប្រតិបត្តិការជារូបិយប័ណ្ណប្រាក់ដុល្លារ និងថៃបាត ត្រូវបានប្តូរទៅជាប្រាក់រៀល ដោយប្រើអត្រាប្តូរប្រាក់នៅថ្ងៃប្រតិបត្តិការនោះ។ សមតុល្យនៃទ្រព្យសកម្មរូបិយវត្ថុ និងបំណុលរូបិយវត្ថុនាកាលបរិច្ឆេទរាយការណ៍ ដែលជារូបិយប័ណ្ណក្រៅពីប្រាក់រៀលក៏ត្រូវបានប្តូរទៅជាប្រាក់រៀលដោយប្រើអត្រានាកាលបរិច្ឆេទនោះ។ ភាពលម្អៀងពីការប្តូររូបិយប័ណ្ណដែលកើតមកពីការប្តូរនោះត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍លទ្ធផល។

## ង-ផលប៉ះពាល់នៃអតិផរណា

អិលអូអិលស៊ី មិនបានកែប្រែអត្រាការប្រាក់ ដោយផ្អែកតាមការប្រែប្រួលនៃអតិផរណាទេ ពោលគឺផ្អែកទៅលើស្ថានភាពប្រកួតប្រជែងជាក់ស្តែងនៅក្នុងទីផ្សារ ហើយនៅតែរក្សាបាននូវចីរភាពហិរញ្ញវត្ថុយ៉ាងល្អប្រសើរ។

## ច-គោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុរបស់រាជរដ្ឋាភិបាល

នាដំណាច់ការិយបរិច្ឆេទ ថ្ងៃទី៣០ ខែកញ្ញា ឆ្នាំ២០១៩ នេះ គណៈគ្រប់គ្រងយល់ថា អិលអូអិលស៊ី ពុំបានទទួលរងការប៉ះពាល់ពីគោលនយោបាយសេដ្ឋកិច្ច សារពើពន្ធ និងរូបិយវត្ថុ របស់រដ្ឋាភិបាលជាសារវន្តនោះទេ។

## ផ្នែកទី ៥៖ ព័ត៌មានចាំបាច់ផ្សេងទៀតសម្រាប់ការពារវិនិយោគិន (ប្រសិនមាន)

## ហត្ថលេខាអភិបាលរបស់បុគ្គលចុះបញ្ជីលក់មូលបត្រ

(ត្រូវចុះហត្ថលេខាដោយប្រធានក្រុមប្រឹក្សាភិបាល ឬអភិបាលយ៉ាងតិច ២រូប)

កាលបរិច្ឆេទ៖ 29 វិច្ឆិកា ឆ្នាំ 2019

បានអាន និងឯកភាព

ប្រ៊ីនឡី ដេ ហ្ស៊ីលវ៉ា

ប្រធានក្រុមប្រឹក្សាភិបាល

គំនិតរីកចម្រើន Ideas for Growth

អគារលេខ ៦៦បេ ផ្លូវលេខ២៧១ ភូមិក្បាលទំនប់១ សង្កាត់បឹងទំពុនទី២ ខណ្ឌមានជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរសព្ទលេខ៖ (+៨៥៥) ២៣ ៩៩១ ៩៩១ | អ៊ីម៉ែល៖ info@lolc.com.kh | Facebook: facebook.com/lolccambodia

គេហទំព័រ៖ www.lolc.com.kh

ឯកសារសាធារណៈ